**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១០៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ដែលសរសេរជាអក្សរកាត់ថា **ក.ជ.ប.ស.** ដើម្បីសិក្សាស្រាវជ្រាវនិងអភិវឌ្ឍបទប្បញ្ញត្តិជាតិបច្ចេកទេសសំណង់ ប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព។

## ជំពូកទី២
## សមាសភាព តួនាទី និងភារកិច្ច

**មាត្រា២ .-**

**គ.ជ.ប.ស.** មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| ២- | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | អនុប្រធាន |
| ៣- | រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | អនុប្រធាន |
| ៤- | រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល | អនុប្រធាន |
| ៥- | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់១រូប | អនុប្រធានប្រចាំការ |
| ៦- | រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ១រូប | សមាជិក |
| ៧- | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ១រូប | សមាជិក |
| ៨- | រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម១រូប | សមាជិក |
| ៩- | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍១រូប | សមាជិក |
| ១០- | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី១រូប | សមាជិក |
| ១១- | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ១រូប | សមាជិក |
| ១២- | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | សមាជិក |
| ១៣- | រដ្ឋលេខាធិការក្រសួងបរិស្ថាន១រូប | សមាជិក |
| ១៤- | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា១រូប | សមាជិក |
| ១៥- | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា១រូប | សមាជិក |
| ១៦- | រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ១រូប | សមាជិក |
| ១៧- | អគ្គលេខាធិការនៃគណៈវិស្វករកម្ពុជា | សមាជិក |
| ១៨- | អគ្គលេខាធិការនៃគណៈស្ថាបត្យករកម្ពុជា | សមាជិក |
| ១៩- | អគ្គនាយកវិទ្យាស្ថានស្តង់ដារកម្ពុជា | សមាជិក |
| ២០- | អគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ២១- | អគ្គនាយកមន្ទីរពិសោធន៍ជាតិសំណង់ | សមាជិក |
| ២២- | តំណាងគ្រឹះស្ថានឧត្តមសិក្សានិងគ្រឹះស្ថានស្រាវជ្រាវពាក់ព័ន្ធមួយចំនួន | សមាជិក |
| ២៣- | ប្រធានសមាគមអ្នកសាងសង់កម្ពុជា | សមាជិក |
| ២៤- | ប្រធានសមាគមអ្នកអភិវឌ្ឍលំនៅឋានកម្ពុជា | សមាជិក |
| ២៥- | ប្រធានសមាគមអ្នកវាយតម្លៃនិងភ្នាក់ងារអចលនវត្ថុកម្ពុជា | សមាជិក |
| ២៦- | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ | សមាជិកអចិន្ត្រៃយ៍។ |

ក្រៅពីសមាសភាពខាងលើ **គ.ជ.ប.ស.** អាចស្នើបន្ថែមសមាសភាពជាតំណាងក្រសួង ស្ថាប័ន ឬឥស្សរជននៃរាជរដ្ឋាភិបាល។

សមាសភាពជាក់ស្តែងរបស់ **គ.ជ.ប.ស.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៣ .-**

**គ.ជ.ប.ស.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងលើកសំណើជូនរាជរដ្ឋាភិបាលដើម្បីដាក់ឱ្យប្រើបទប្បញ្ញត្តិជាតិបច្ចេកទេសសំណង់
- ផ្តល់យោបល់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីដាក់ឱ្យប្រើបទប្បញ្ញត្តិបច្ចេកទេសសំណង់ដទៃទៀត ស្របតាមលក្ខខណ្ឌសេដ្ឋកិច្ច សង្គម បរិស្ថាន បច្ចេកវិទ្យា និងវិទ្យាសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា
- តាមដានការអនុវត្តនិងលើកសំណើឬផ្តល់យោបល់កែសម្រួលបទប្បញ្ញត្តិបច្ចេកទេសសំណង់ដើម្បីឱ្យស្របតាមការវិវឌ្ឍនៃសេដ្ឋកិច្ច សង្គម បរិស្ថាន បច្ចេកវិទ្យា និងវិទ្យាសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា
- កំណត់វិធាននិងផ្តល់គោលការណ៍ណែនាំក្នុងការសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិបច្ចេកទេសសំណង់
- ធ្វើកិច្ចសហប្រតិបត្តិការនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន គ្រឹះស្ថានស្រាវជ្រាវ អ្នកស្រាវជ្រាវ និងវិស័យឯកជន ដើម្បីសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិបច្ចេកទេសសំណង់
- ធ្វើកិច្ចសហប្រតិបត្តិការនិងសម្របសម្រួលជាមួយដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ ដើម្បីកៀរគរធនធានមនុស្សនិងធនធានហិរញ្ញវត្ថុ ដើម្បីគាំទ្រសកម្មភាពសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិបច្ចេកទេសសំណង់
- បណ្តុះបណ្តាលនិងផ្សព្វផ្សាយដល់ក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល វិស័យឯកជន អ្នកវិជ្ជាជីវៈ និងសាធារណជនអំពីបទប្បញ្ញត្តិបច្ចេកទេសសំណង់
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជូនរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីរាជរដ្ឋាភិបាល។

## ជំពូកទី៣
## ការប្រព្រឹត្តទៅ

**មាត្រា៤ .-**

ប្រធាន **គ.ជ.ប.ស.** ដឹកនាំកិច្ចការទូទៅរបស់ **គ.ជ.ប.ស.**។ ក្នុងករណីអវត្តមាន ប្រធាន **គ.ជ.ប.ស.** អាចប្រគល់សិទ្ធិជូនអនុប្រធាន **គ.ជ.ប.ស.** ណាម្នាក់ឱ្យទទួលដឹកនាំការងារប្រចាំថ្ងៃរបស់ **គ.ជ.ប.ស.** ក្នុងឋានៈជាប្រធានស្តីទីរហូតដល់មានវត្តមានប្រធាន **គ.ជ.ប.ស.**។

អនុប្រធាន **គ.ជ.ប.ស.** អនុវត្តការងារតាមការកំណត់របស់ប្រធាន ដូចមានចែងក្នុងសេចក្តីសម្រេចស្តីពីការបែងចែកភារកិច្ច។

**មាត្រា៥ .-**

**គ.ជ.ប.ស.** ត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួនយ៉ាងតិច២(ពីរ)ដងក្នុងមួយឆ្នាំ។ ក្នុងករណីចាំបាច់ **គ.ជ.ប.ស.** អាចប្រជុំជាវិសាមញ្ញតាមការកោះអញ្ជើញរបស់ប្រធាន **គ.ជ.ប.ស.**។

របៀបរបបការងារនិងកិច្ចដំណើរការប្រជុំរបស់ **គ.ជ.ប.ស.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **គ.ជ.ប.ស.**។

**គ.ជ.ប.ស.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន ឥស្សរជន ដៃគូអភិវឌ្ឍ វិស័យឯកជន អ្នកជំនាញការជាតិ និងអន្តរជាតិដែលមានបទពិសោធ សមត្ថភាព និងជំនាញវិជ្ជាជីវៈ ដើម្បីចូលរួមប្រជុំពិគ្រោះយោបល់និងបំភ្លឺលើរាល់បញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងក្របខ័ណ្ឌការងាររបស់ខ្លួន។

ដើម្បីបំពេញការងារប្រកបដោយប្រសិទ្ធភាពជូនរាជរដ្ឋាភិបាល **គ.ជ.ប.ស.** អាចស្នើសុំឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ ផ្តល់ឯកសារ ទិន្នន័យ និងព័ត៌មាននានាដែលទាក់ទងនឹងការសិក្សា ការស្រាវជ្រាវ និងការអភិវឌ្ឍបទប្បញ្ញត្តិបច្ចេកទេសសំណង់របស់ **គ.ជ.ប.ស.** បាន។

**មាត្រា៦ .-**

**គ.ជ.ប.ស.** មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការសម្រាប់ដំណើរការការងារប្រចាំថ្ងៃ។

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ត្រូវដឹកនាំដោយអគ្គលេខាធិការ ១(មួយ)រូប និងមានអគ្គលេខាធិការរងមួយចំនួនជាជំនួយការអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

**មាត្រា៧ .-**

**គ.ជ.ប.ស.** មានរូបសញ្ញាផ្ទាល់ខ្លួននិងមានសិទ្ធិប្រើត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងការបំពេញការងារ។

រូបសញ្ញារបស់ **គ.ជ.ប.ស.** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី៤
## ប្រភពធនធាន

**មាត្រា៨ .-**

**គ.ជ.ប.ស.** មានធនធានសម្រាប់អនុវត្តសកម្មភាពការងារដោយថវិកាជាតិ នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**គ.ជ.ប.ស.** មានសិទ្ធិទទួលនិងគ្រប់គ្រងតាមនីតិវិធីហិរញ្ញវត្ថុជាធរមាននូវមូលនិធិដែលបានមកពីហិរញ្ញប្បទានឥតសំណង ជំនួយបច្ចេកទេស និងពីប្រភពស្របច្បាប់ផ្សេងៗទៀត សម្រាប់បំពេញភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៧កើត ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០២២
ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់

## រូបសញ្ញារបស់ ក.ជ.ប.ស.

## អត្ថន័យនៃរូបសញ្ញា
## ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់

១- ពណ៌ខៀវ តំណាងឱ្យព្រះមហាក្សត្រ សាមគ្គីភាព ភាតរភាព សន្តិភាព និងភាពត្រជាក់ត្រជុំ រុងរឿងថ្កុំថ្កើង។

២- ពណ៌ក្រហមផ្នែកកណ្តាល តំណាងឱ្យជាតិនិងស្មារតីអង់អាចក្លាហាន ពុះពារ គ្រប់ឧបសគ្គ ក្នុងការតាក់តែងបទប្បញ្ញត្តិបច្ចេកទេសសំណង់និងការអនុវត្តច្បាប់។

៣- អក្សរពណ៌ស តំណាងឱ្យសាសនា ក្រមសីលធម៌ ចរិយាធម៌ និងការគោរពច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

៤- ត្រៃរង្គ មានបួពណ៌ខៀវ ក្រហម ចារឹកដោយអក្សរពណ៌ស។ ពណ៌ទាំងបីតំណាងឱ្យបាវចនាជាតិ សាសនា ព្រះមហាក្សត្រ និងមានទម្រង់ជារង្វង់មូល តំណាងឱ្យការរួបរួមគ្នាតែមួយ។

៥- ព្រះវិស្សកម្មទេវបុត្រ ឬព្រះពិស្ណុការ គង់នៅលើព្រះបល្ល័ង្ក ព្រះហស្តស្តាំកាន់កូនប្រយោលតំណាងឱ្យបច្ចេកទេសសំណង់ទាំងឡាយ និងព្រះហស្តឆ្វេងកាន់ក្បួនច្បាប់ តំណាងឱ្យអ្នកសម្រេចកិច្ចការសព្វបែបយ៉ាងផ្នែកខាងក្បួនច្បាប់សំណង់ និងសិល្បសាស្ត្រ។

៦- ក្បាច់ភ្ញីភ្លើង តំណាងឱ្យតេជានុភាព និងការផ្សាយនូវអំណាចក្នុងការអនុវត្តបទប្បញ្ញត្តិបច្ចេកទេសសំណង់ ប្រកបដោយភាពរុងរឿង និងសុខដុមនីយកម្ម។

៧- ផ្ទៃខាងក្រោយពណ៌ផ្ទៃមេឃរាងមូល តំណាងឱ្យចក្រវាល លម្ហអាកាស និងភាពយុត្តិធម៌។